**កំណត់សម្គាល់ការសិក្សា:** ម៉ូឌុលនេះត្រូវប្រើពេលប្រហែលប្រាំម៉ោង ។ ប្រសិនបើ អ្នកមានពេលតិចតួច អ្នកអាចផ្អាកការសិក្សាដោយសមរម្យបន្ទាប់ពីភាគនៃសម្លេងភាគទី៤ ។

# ម៉ូឌុល ៧: ប្រកាសនីយបត្រតក្កកម្ម

**គោលបំណង** បន្ទាប់ពីបានបញ្ចប់ការសិក្សានៃម៉ូឌុលនេះ អ្នកអាច ៖

១.ពិពណ៌នាអំពីគោលបំណងនៃប្រកាសនីយបត្រតក្កកម្មឲ្យបាន១០០ពាក្យ ។
២.ធ្វើជាតារាង ស្តីពី ល័ក្ខខ័ណ្ឌដែលត្រូវបានទទួលស្គាល់ជាទូទៅសម្រាប់ការទទួលបានប្រកាសនីយប័ត្រតក្កកម្ម។
៣.ពិពណ៌នាអំពីសិទ្ធិផ្តាច់មុខដែលទទួលបានពីប្រកាសនីយប័ត្រតក្កកម្ម ។
៤.លើកឡើងពីបុគ្គលដែលទទួលខុសត្រូវចំពោះការផ្តួចផ្តើមគំនិតអនុវត្តប្រកាសនីយប័ត្រតក្កកម្មនេះ ។
៥.ពន្យល់ថាតើហេតុអ្វីបានជាប្រកាសនីយប័ត្រតក្កកម្មតម្រូវឲ្យមាននៅក្នុងប្រទេសណាមួយសិន មុននឹងអ្នកអាចប្តឹងអ្នករំលោភនៅក្នុងប្រទេសនោះបាន ។
៦. ពិពណ៌នាអំពី នីតិវិធីដែលត្រូវអនុវត្តក្នុងករណីដែលពាក្យស្នើសុំប្រកាសនីយប័ត្រតក្កកម្មត្រូវបានដាក់ពាក្យជាលក្ខណ:ជាតិ ជាលក្ខណ:តំបន់ ឬតាមរយ:សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្ម(PCT) ។

## សេចក្តីផ្តើម

ប្រកាសនីយប័ត្រតក្កកម្មគឺជាទម្រង់ចាស់មួយស្តីពីកិច្ចការពារកម្មសិទ្ធិបញ្ញា ហើយដូចទម្រង់ទាំងអស់នៃកិច្ចការពារកម្មសិទ្ធិបញ្ញាដែរ គោលបំណងនៃប្រព័ន្ធប្រកាសនីយប័ត្រតក្កកម្មគឺដើម្បីលើកទឹកចិត្តដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងបច្ចេកវិទ្យាដោយផ្តល់ជារង្វាន់ចំពោះការច្នៃប្រឌិតខាងបញ្ញា ។ ម៉ូឌុលនេះនឹងពន្យល់អ្នកនូវគោលបំណងនៃប្រកាសនីយបត្រតក្កកម្ម ផលប្រយោជន៍នៃការទទួលបាននូវប្រកាសនីយប័ត្រតក្កកម្ម តើប្រភេទនៃទំនិញអ្វីខ្លះដែលអាចទទួលបានប្រកាសនីយប័ត្រតក្កកម្ម និងកិច្ចការពារដោយប្រកាសនីយប័ត្រតក្កកម្មមានរយ:ពេលប៉ុន្មាន ។ មានការពន្យល់ផងដែរអំពីចរិកលក្ខណ:នៃប្រព័ន្ធប្រកាសនីយប័ត្រតក្កកម្មអន្តរជាតិ ។

# ប្រកាសនីយប័ត្រតក្កកម្ម

## តើប្រកាសនីយប័ត្រតក្កកម្ម គឺជាអ្វី ?

យើងនាំគ្នាចាប់ផ្តើមពិចារណា ថាតើអ្វីទៅជាប្រកាសនីយប័ត្រតក្កកម្ម ។ នៅពេលដែលពាក្យស្នើសុំត្រូវបានចេញដោយការិយាល័យរបស់រដ្ឋាភិបាល(ជាទូទៅការិយាល័យប្រកាសនីយប័ត្រតក្កកម្ម) ប្រកាសនីយប័ត្រតក្កកម្មជាឯកសារមួយដែលពិពណ៌នាអំពីតក្កកម្មមួយ និងបង្កើតបានជាស្ថានការណ៍ច្បាប់មួយដែលជាទូទៅ តក្កកម្មត្រូវបានធ្វើអាជីវកម្មដោយមានការអនុញ្ញាតពីម្ចាស់ប្រកាសនីយប័ត្រតក្កកម្មតែប៉ុណ្ណោះ ។ ម្យ៉ាងទៀតប្រកាសនីយប័ត្រតក្កកម្មការពារតក្កកម្មមួយ និងផ្តល់សិទ្ធិផ្តាច់មុខដល់ម្ចាស់សិទ្ធិដើម្បីប្រើប្រាស់តក្កកម្មរបស់ខ្លួននៅក្នុងរយៈពេលមួយមានកំណត់ ។ ហើយតក្កកម្មមួយអាចត្រូវបានកំណត់ថាជាដំណោះស្រាយថ្មីមួយចំពោះបញ្ហាបច្ចេកទេស ។

ឧទាហរណ៍ស្តីពីតក្កកម្ម : បន្ទះបិទរបួសឆ្នាំងអ៊ុតអគ្គីសនីម្ភូលខ្វាស់ ប៊ិច ទូរស័ព្ទ ។ល។

ឥឡូវនេះ យើងនាំគ្នាស្តាប់ភាគនៃសម្លេងបន្ទាប់ដែលពន្យល់អំពីគោលបំណង និងប្រវត្តិនៃកិច្ចការពារប្រកាសនីយប័ត្រតក្កកម្ម ។

## ភាគនៃសម្លេងភាគទី១ : អ្នកអាចប្រាប់ខ្ញុំបានឬទេ តើអ្វីទៅជាគោលបំណងរបស់ប្រកាសនីយបត្រតក្កកម្ម?

គោលបំណងនៃប្រកាសនីយប័ត្រតក្កកម្មគឺផ្តល់ទម្រង់នៃកិច្ចការពារបច្ចេកវិទ្យាទំនើប ។ ទ្រឹស្តីគឺថា កិច្ចការពារប្រកាសនីយប័ត្រតក្កកម្មមិនត្រឹមតែផ្តល់រង្វាន់ដល់ការបង្កើតតក្កកម្មមួយប៉ុណ្ណោះទេ ថែមទាំងសម្រាប់ការអភិវឌ្ឍន្ទូវតក្កកម្មដែលអាចសម្រេចបាននិងអាចមានទីផ្សារ ហើយប្រភេទនៃការលើកទឹកចិត្តនេះនឹងជម្រុញបន្ថែមនូវការច្នៃប្រឌិតថ្មី និងលើកទឹកចិត្តដល់ក្រុមហ៊ុនដើម្បីបន្តនូវការអភិវឌ្ឍន៍បច្ចេកវិទ្យាថ្មីៗដែលពាក់ព័ន្ធទៅនឹងតក្កកម្មដែលមានទីផ្សារ មានសារៈប្រយោជន៍ដល់សាធារណជននិងបំពេញតម្រូវការទំនិញសាធារណៈ ។

## ភាគនៃសម្លេងភាគទី២ : តើប្រព័ន្ធប្រកាសនីយប័ត្រតក្កកម្មចាប់ផ្តើមនៅពេលណា ?

ប្រព័ន្ធប្រកាសនីយប័ត្រតក្កកម្មត្រូវបានបង្កើតឡើងជាច្រើនសតវត្សកន្លងមកហើយ ។ មានប្រកាសនីយប័ត្រតក្កកម្មជាច្រើនត្រូវបានបង្កើតឡើងក្នុងទសវត្ស ឆ្នាំ១៧០០ ។ ប្រព័ន្ធនេះបានវិវឌ្ឍនៅក្នុងឆ្នាំនេះហើយបច្ចុប្បន្ននេះយើងមានប្រព័ន្ធទំនើបមួយ ។ យើងនៅតែកំពុងបង្កើតប្រព័ន្ធអន្តរជាតិដើម្បីធ្វើឲ្យប្រព័ន្ធនេះកាន់តែទំនើប ហើយទន្ទឹមគ្នានេះដើម្បីរក្សាបាននូវការប្រែប្រួលខាងបច្ចេកវិទ្យា និងការប្រែប្រួលនៃប្រព័ន្ធសេដ្ឋកិច្ច ។




**SAQ 1: តើអ្វីទៅដែលជាគោលបំណងសំខាន់របស់ប្រកាសនីយប័ត្រតក្កកម្ម?**

**ចូរអ្នកវាយចម្លើយរបស់អ្នកនៅត្រង់នេះ:**

| |
|---|
| |

**ចុចត្រង់នេះ ដើម្បីមើលចម្លើយ:**

**SAQ 1: ចម្លើយ**

គោលបំណងរបស់ប្រកាសនីយប័ត្រតក្កកម្មគឺ ផ្តល់នូវកិច្ចការពារសម្រាប់ភាពជឿនលឿននៃបច្ចេកវិទ្យា (តក្កកម្ម) ។ គោលបំណងនេះនឹងផ្តល់នូវរង្វាន់ចំពោះការលាតត្រដាងឲ្យដឹងអំពីការបង្កើតទំនិញថ្មីព្រមទាំងការអភិវឌ្ឍន៍បន្ថែម ឬការចម្រាញ់បច្ចេកវិទ្យាដែលមានស្រាប់ ។ សរុបសេចក្តីទៅ តាមរយៈ

ប្រកាសនីយបត្រតក្កកម្ម វឌ្ឍនភាពនៅក្នុងការផ្លាស់ប្តូរបច្ចេកវិទ្យាជួយជម្រុញឱ្យមានភាពកាន់តែល្អប្រសើរឡើង ។

ឥឡូវនេះ ចូរអ្នកស្តាប់ភាគនៃសម្លេងបន្ទាប់ដើម្បីស្វែងយល់ពីវិធីដែលប្រកាសនីយប័ត្រតក្កកម្មផ្តល់កិច្ចការពារនិងកម្មវត្ថុដែលមិនអាចត្រូវបានការពារដោយប្រកាសនីយបត្រតក្កកម្ម ។

**ភាគនៃសម្លេងភាគទី៣: តើប្រភេទនៃផលិតផលដែលអាចត្រូវបានការពារ មានអ្វីខ្លះ ?**

តាមរយៈកិច្ចព្រមព្រៀងអន្តរជាតិ ប្រកាសនីប័ត្រតក្កកម្មអាចមានសម្រាប់តក្កកម្មណាមួយទាំងដំណើរការផលិតកម្ម ឬផលិតផលគ្រប់វិស័យបច្ចេកវិទ្យាទាំងអស់។ សមាសធាតុគីមីក៏អាចត្រូវបានទទួលនូវប្រកាសនីប័ត្រតក្កកម្មផងដែរ ។ ជាការពិត ម៉ាស៊ីនមួយអាចត្រូវបានទទួលប្រកាសនីយបត្រតក្កកម្ម ។ ដំណើរការអភិវឌ្ឍ ឬការផលិតទំនិញអាចត្រូវបានទទួលប្រកាសនីប័ត្រតក្កកម្ម ។ ទោះបីយ៉ាងណាក៏មានទំនិញដែលមិនអាចត្រូវបានទទួលប្រកាសនីប័ត្រតក្កកម្ម ហើយជាទូទៅមិនបានរាប់បញ្ចូលនូវវិសាលភាពនៃការទទួលបានប្រកាសនីយប័ត្រតក្កកម្មនោះឡើយ ។ ឧទាហរណ៍ដូចជាហ្សែនរបស់មនុស្សមិនអាចត្រូវបានទទួលប្រកាសនីប័ត្រតក្កកម្មទេ ។ វត្ថុដែលមានរួចហើយក្នុងធម្មជាតិមិនអាចទទួលបានប្រកាសនីយបត្រតក្កកម្មនោះទេ តែមានករណីលើកលែងតិចតួច។ ម៉ាស៊ីនធ្វើចលនាឥតឈប់ដែលដំណើរការប្រឆាំងនឹងច្បាប់ធម្មជាតិមិនអាចត្រូវបានទទួលប្រកាសនីយប័ត្រតក្កកម្មទេ លុះត្រាតែគេអាចបង្ហាញថាម៉ាស៊ីននោះអាចដំណើរការទៅបាន។ បន្ទាប់មក ជាការពិតវិធានចាស់ត្រូវបានទុកដោយឡែកសិន ហើយរឿងដែលថ្មីត្រូវបានបង្កើតឡើង ។ តក្កកម្មមួយចំនួនអាចមិនត្រូវបានរាប់បញ្ចូលក្នុងវិសាលភាពនៃការទទួលបានប្រកាសនីយប័ត្រតក្កកម្មនោះទេ សម្រាប់មូលដ្ឋានសណ្តាប់ធ្នាប់សាធារណៈឬសីលធម៌ ។

ប្រកាសនីយប័ត្រតក្កកម្មមានបំណងស្វែងរកនូវបច្ចេកវិទ្យា ប៉ុន្តែប្រកាសនីប័ត្រតក្កកម្មក៏មានបំណងផងដែរសម្រាប់បង្កើនចំនួនបច្ចេកវិទ្យាខ្នាតតូច ដូច្នេះការអភិវឌ្ឍដែលកើតឡើងនៅក្នុងវិស័យបច្ចេកវិទ្យាណាមួយដែលអាចទទួលបានប្រកាសនីយប័ត្រតក្កកម្មអាចជាការអភិវឌ្ឍដ៏អស្ចារ្យមួយដូចជាតក្កកម្មនៃថ្នាំប៉េនីស៊ីលីន ឬការកែលំអតិចតួចដូចជាសមត្ថភាពថ្មីនៃម៉ាស៊ីនដែលអាចដំណើរការបានលឿនជាងមុន ។ ប្រភេទផលិតផលទាំងនេះអាចត្រូវបានទទួលប្រកាសនីយប័ត្រតក្កកម្ម ។

ដូច្នេះប្រកាសនីប័ត្រតក្កកម្មការពារតក្កកម្មដែលថ្មីនិងមានប្រយោជន៍។ អ្នកបានដឹងអំពីប្រភេទតក្កកម្មខ្លះៗដែលអាចត្រូវបានការពារដោយប្រកាសនីប័ត្រតក្កកម្ម និងប្រភេទដែលបានលើកលែងទូទៅមួយ

ចំនួនផងដែរ ។ ដើម្បីទទួលបានប្រកាសនីប័ត្រតក្កកម្ម តក្កកម្មមួយត្រូវតែបំពេញលក្ខណៈវិនិច្ឆ័យមួយចំនួនពាក់ព័ន្ធនឹងភាពថ្មី និងលក្ខណៈវិនិច្ឆ័យដ៏ទៃទៀត ។ កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា(TRIPS Agreement)ចែងអំពីលក្ខណៈវិនិច្ឆ័យបីយ៉ាង និងល័ក្ខខ័ណ្ឌដែលអាចទទួលបានប្រកាសនីប័ត្រតក្កកម្ម ។

ចូរអ្នកស្តាប់សម្លេងដែលលើកឡើងអំពី ល័ក្ខខ័ណ្ឌចំនួនបីសម្រាប់ការទទួលបានប្រកាសនីយបត្រតក្កកម្ម ។

**ភាគនៃសម្លេងទី៩: អ្នកបានលើកឡើងខ្លះៗរួចហើយពីលក្ខណៈវិនិច្ឆ័យទាំងនេះ ។ ប៉ុន្តែជារួម តើមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ដើម្បីឱ្យតក្កកម្មមួយអាចទទួលបានប្រកាសនីប័ត្រតក្កកម្ម ?**




មានលក្ខណៈវិនិច្ឆ័យច្រើនយ៉ាង ដែលការិយាល័យប្រកាសនីយប័ត្រតក្កកម្មត្រូវពិនិត្យមើល ដើម្បីកំណត់ថាតើតក្កកម្មអាចត្រូវបានទទួលប្រកាសនីយប័ត្រតក្កកម្ម។ ជាបឋមត្រូវមានសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ។ មានករណីជាច្រើនសំណុំលិខិតស្នើសុំប្រកាសនីយប័ត្រតក្កកម្មត្រូវបានត្រួតពិនិត្យដោយអ្នកជំនាញបច្ចេកទេស ដើម្បីធានាថាពាក្យស្នើសុំនោះបានបំពេញលក្ខណៈវិនិច្ឆ័យខ្លឹមសារសម្រាប់ទទួលបានប្រកាសនីយបត្រតក្កកម្ម ។

លក្ខណៈវិនិច្ឆ័យទី១គឺថា តក្កកម្មត្រូវតែថ្មី (ភាពថ្មី) មានន័យថា តក្កកម្មមិនដែលត្រូវបានផលិតពីមុនអនុវត្តពីមុនឬប្រើប្រាស់ពីមុនមកទេ ។
លក្ខណៈវិនិច្ឆយទី២គឺត្រូវមានជំហានរកឃើញថ្មី។ ម៉្យាងទៀត លក្ខណៈវិនិច្ឆ័យទីពីរនេះត្រូវតែតំណាងឲ្យភាពជឿនលឿននិងមានលក្ខណៈគ្រប់គ្រាន់ដែលពាក់ព័ន្ធទៅនឹងស្នាដៃមុនមុនពេលដែលលក្ខណៈវិនិច្ឆ័យនេះត្រូវបានចាត់ទុកថាអាចទទួលបានប្រកាសនីយប័ត្រតក្កកម្មដ៏មានតម្លៃ ។

ពាក្យ " **មិនជាក់ស្តែង**" ត្រូវបានយកមកប្រើប្រាស់ផងដែរៈប្រសិនបើវាជាក់ស្តែងពេកចំពោះបុគ្គលដែលមានជំនាញធម្មតានៅក្នុងវិស័យដែលពាក់ព័ន្ធនោះ វាមិនអាចឈានដល់ដំណាក់ការដែលអាចទទួលបានកិច្ចការពារដោយប្រកាសនីយបត្រតក្កកម្មនោះឡើយ ។

លក្ខណៈវិនិច្ឆ័យទី៣គឺត្រូវអាចយកទៅអនុវត្តបាននៅក្នុងវិស័យឧស្សាហកម្ម ។ វាត្រូវតែអាចយកទៅប្រើប្រាស់នៅក្នុងវិធីណាមួយ ។ នេះគឺជាលក្ខណៈវិនិច្ឆ័យដ៏ទូលំទូលាយបំផុត។ ស្ទើរតែវត្ថុទាំងអស់អាចត្រូវបានប្រើប្រាស់ ទោះបីវាស្ថិតនៅក្នុងដំណាក់ការស្រាវជ្រាវក៏ដោយប៉ុន្តែដូចដែលខ្ញុំបានលើកឡើងរួចមកហើយ វាមិនអនុវត្តចំពោះម៉ាស៊ីនដែលធ្វើចលនាឥតឈប់នោះទេពីព្រោះជាទូទៅមិនដំណើរការ ។

ហេតុដូច្នេះ និយាយដោយសង្ខេប ដើម្បីអាចទទួលបានប្រកាសនីយបត្រតក្កកម្មតក្កកម្មត្រូវតែថ្មីមានជំហានរកឃើញថ្មី និងអាចយកទៅអនុវត្តបាននៅក្នុងវិស័យឧស្សាហកម្ម ។

**<u>ប្រដាប់បូមតូចល្អិតដែលអាចដាក់ចូលក្នុងរាងកាយបាន</u>**

ប្រដាប់បូមតូចល្អិតដែលអាចដាក់ចូលក្នុងរាងកាយបាន(MIP)នោះគឺជា ផ្នែកនៃគ្រួសារមួយស្តីអំពីប្រដាប់បូមតូចល្អិតធ្វើពីសារធាតុស៊ីលីសដែលអាចជួយជម្រុញ piezo បង្កើតឡើងដោយ Debiotechសម្រាប់បញ្ជូនឱសថ ។ ទោះបីទំហំរបស់វា (១៦x១២x១.៨៦មម.)ក៏ដោយក៏គ្រឿងបច្ចេកវិទ្យានេះមាន១៧តក្កកម្ម ដែលគ្របដណ្តប់ដោយ៤៩ប្រកាសនីយប័ត្រតក្កកម្ម ។



**<u>បញ្ជីតក្កកម្ម(ចំណងជើង)</u>**:

១) រន្ធដែលមានផ្នុកសម្រាប់បូម

២) រ៉ូលីម(នៃស្វរសម្លេង)ដាក់នៅឆ្ងាយពីរន្ធ

៣) សន្ទះមិនអាចមូលបានដោយមានមានភ្ជាប់គ្រឿងផ្សេងៗ

៤) សន្ទះដែលមានទ្រនាប់ស្បែកស្តើងៗសម្រាប់ខ័ណ្ឌខ្សែទឹកឡើងចុះ

៥) វិធីឆ្លាក់ដាក់អាស៊ីដឲ្យស៊ីដើម្បីទទួលបានរន្ធមួយ

៦) សន្ទះមានរាងកោងហើយបិទជិតនៅពេលដែលគ្មានឥទ្ធិពលពីខាងក្រៅ

៧) សន្ទះចំហនៅពេលដែលគ្មានទ្រនាប់ទី២

៨) សន្ទះមួយមានភ្ជាប់គ្រឿងផ្សេងៗសម្រាប់ចាប់អ្វីមួយ

៩) បន្ទះមានផ្នុកពីរដែលអាចផ្លាស់ប្តូរបាន

១០) ប្រដាប់បូមតូចល្អិតដែលបឺតទឹកខ្លួនឯង

១១)តំណនៃសមាសធាតុធ្វើអំពីកែវមានទ្រនាប់ធ្វើអំពីមាស

១២)តំណនៃសមាសធាតុធ្វើអំពីដែកដែលមានលក្ខណៈជួសជុល

១៣)តម្រងប្រដាប់បូមតូចល្អិត

១៤)ការធ្វើស្ដីដែលបង្ហាញពីភាពខុសគ្នា

១៥)បន្ទះដែកស្តើង

១៦)បន្ទះមធ្យមដែលបានបញ្ចូលគ្នា

១៧)សន្ទះក្រាស់

**លេខប្រកាសនីយប័ត្រតក្កកម្ម:**

មាន៩៤ប្រកាសនីយប័ត្រតក្កកម្មត្រូវបានផ្តល់កិច្ចការពារតក្កកម្មទាំងនេះ ។

**SAQ ២តើ " ជំហានរកឃើញថ្មី " ដូចម្តេចដែលត្រូវបានទទួលស្គាល់ ?**

ចូរអ្នកវាយចម្លើយរបស់អ្នក នៅត្រង់នេះ:

ចូរចុចត្រង់នេះដើម្បីមើលចម្លើយ

**SAQ 2 ចម្លើយ :**

ជំហានរកឃើញថ្មីមួយជាលក្ខខណ្ឌចាំបាច់មួយក្នុងការផ្តល់ប្រកាសនីយបត្រតក្កកម្ម។ ប៉ុន្តែ តក្កកម្មនេះត្រូវតែមានការអភិវឌ្ឍគ្រប់គ្រាន់ ទើបចាត់ទុកថាមានជំហានរកឃើញថ្មី ដោយបុគ្គលដែលមានជំនាញធម្មតាក្នុងស្នាដៃ។ ប្រសិនបើ តក្កកម្មនេះមានភាពច្បាស់ពេកចំពោះបុគ្គលដែលមានជំនាញធម្មតាក្នុងស្នាដៃបច្ចេកវិទ្យាដែលមានស្រាប់នោះតក្កកម្មនោះមិនអាចទទួលប្រកាសនីយប័ត្រតក្កកម្មនោះឡើយ

## សំណួរវាយតម្លៃខ្លួនឯង

**SAQ ៣ តើភាពអាចអនុវត្តបានក្នុងវិស័យឧស្សាហកម្ម ត្រូវបានកំណត់យ៉ាងដូចម្តេច ?**

ចូរអ្នកសរសេរចម្លើយរបស់អ្នក នៅត្រង់នេះ:

ចុច នៅត្រង់នេះដើម្បីមើលចម្លើយ

**SAQ ៣ចម្លើយ**

ដើម្បីស្នើសុំនិងកំណត់ពីភាពអាចទទួលបានប្រកាសនីយបត្រតក្កកម្មក្រោម "លក្ខខណ្ឌអាចអនុវត្តបានក្នុងវិស័យឧស្សាហកម្ម" តក្កកម្មត្រូវតែអាចប្រើប្រាស់បានក្នុងការអនុវត្តជាក់ស្តែង។ឧទាហរណ៍ម៉ាស៊ីនដែលធ្វើចលនាឥតឈប់ត្រូវបានលើកឡើងដោយអ្នកឧទ្ទេសនាម និងបានពន្យល់ថា ម៉ាស៊ីននេះមិនអាចទទួលបានប្រកាសនីយប័ត្រតក្កកម្មឡើយ(ដូចករណីនៅក្នុងប្រទេសសហគមអឺរ៉ុបភាគច្រើន) ពីព្រោះវាមិនដំណើរការឲ្យបានត្រឹមត្រូវទេ។

នៅក្នុងប្រទេសជាច្រើន តក្កកម្មមួយត្រូវបានចាត់ទុកថាជាដំណោះស្រាយថ្មីមួយចំពោះបញ្ហាបច្ចេកវិទ្យាមួយ ។ កិច្ចការពារមានចែងនៅក្នុងច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មមិនចាំបាច់តម្រូវឱ្យតក្កកម្មនោះត្រូវតំណាងដោយវត្ថុនោះឡើយ ។ ជាងនេះទៅទៀតវាមិនស្ថិតក្រោមការលើកលែង ឬការដកចេញណាមួយ ដែលចែងក្នុងច្បាប់នោះទេ។

មានគោលការណ៍ណែនាំទូទៅមួយចំនួនពាក់ព័ន្ធនឹងប្រភេទនៃកម្មវត្ថុដែលអាច ឬមិនអាចទទួលបានប្រកាសនីយប័ត្រតក្កកម្មត្រូវបានពិភាក្សានៅក្នុងភាគនៃសម្លេង៣ ។ តើមានករណីលើកលែងណាខ្លះដែលបានលើកឡើងនៅក្នុងភាគនៃសម្លេងនោះ ? ចូរអ្នកស្តាប់ម្តងទៀត ប្រសិនបើអ្នកមិនអាចចងចាំបាន ។

**ករណីលើកលែងដែលបានលើកឡើងនៅក្នុងសម្លេងគឺ:**

វត្ថុដែលមានពីធម្មជាតិត្រូវបានរកឃើញហើយមិនបានប្រឌិតឡើង ។ ជាឧទាហរណ៍ គេមិនអាច "ទទួលបានប្រកាសនីយប័ត្រតក្កកម្ម"លើការរកឃើញភពថ្មីនោះទេ។
ម៉ាស៊ីនដែលប្រឆាំងនឹងច្បាប់ធម្មជាតិ មានដូចជា ម៉ាស៊ីនដែលធ្វើចលនាឥតឈប់ ។

**ការលើកលែងដទៃទៀត ក្រោមច្បាប់ជាតិ និងកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា គឺ:**

ទ្រឹស្តីវិទ្យាសាស្ត្រ ឬវិធីសាស្ត្រផ្នែកគណិតសាស្ត្រ ។

ផែនការ វិធាន វិធីសាស្រ្ត មានដូចជា របៀបធ្វើជំនួញ ការសម្តែងនូវអំពើខាងផ្លូវចិត្ត ឬការលេងល្បែងនានា ។

វិធីសាស្រ្តព្យាបាលមនុស្ស ឬសត្វ ឬវិធីសាស្រ្តផ្នែករោគវិនិច្ឆ័យ( ប៉ុន្តែ ប្រដាប់ប្រដាដែលប្រើប្រាស់នៅក្នុងរោគវិនិច្ឆ័យនោះអាចត្រូវបានទទួលនូវប្រកាសនីយបត្រតកក្កកម្ម ) ។

រុក្ខជាតិ ឬសត្វក្រៅពីមីក្រូសារពាង្គកាយ និងជាពិសេសដំណើរការផ្នែកជីវសាស្រ្តសម្រាប់ការផលិតរុក្ខជាតិក្រៅពីដំណើរការដែលមិនមែនជីវសាស្រ្តនិងមីក្រូសារពាង្គកាយចេញ ។

ដើម្បីទទួលបានប្រកាសនីយបត្រតក្កកម្ម ជាដំបូងអ្នកស្នើសុំត្រូវដាក់សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ។ ការិយាល័យប្រកាសនីយប័ត្រតក្កកម្មត្រូវពិនិត្យសំណុំលិខិតស្នើសុំដើម្បីកំណត់ថាតើបានបំពេញលក្ខណៈវិនិច្ឆ័យដែលបានលើកឡើងខាងលើឬទេមុននឹងសម្រេចចេញប្រកាសនីយប័ត្រតក្កកម្មដោយផ្អែកលើច្បាប់ដែលអាចអនុវត្តបាននោះ ។ ដូចដែលបានពិពណ៌នាខាងលើអាចមានប្រភេទ នៃការលើកលែងមួយចំនួនដែលអាចបណ្តាលឱ្យបរាជ័យក្នុងការទទួលបានប្រកាសនីយបត្រតក្កកម្ម។ ។ ឧទាហរណ៍អំពីប្រភេទនៃការលើកលែងអាចមានចែងនៅក្នុងច្បាប់ជាតិ ។

សំណុំលិខិតស្នើសុំប្រកាសនីយប័ត្រតក្កកម្មត្រូវតែធ្វើតាមទម្រង់បែបបទដទៃទៀតផងដែរ ។ តាមធម្មតា ប្រកាសនីយប័ត្រតក្កកម្ម ត្រូវបានផ្តល់ដល់បុគ្គល ដែលបានដាក់សំណុំលិខិតស្នើសុំប្រកាសនីយប័ត្រតក្កកម្មមុនគេ ។ នេះហៅថាប្រព័ន្ធ " ដាក់ពាក្យស្នើសុំមុន" ។ នេះជាមូលហេតុដែលកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំប្រកាសនីយប័ត្រតក្កកម្មគឺមានសារៈសំខាន់ខ្លាំងណាស់។

ការិយាល័យប្រកាសនីយប័ត្រតក្កកម្មត្រូវពិនិត្យពាក្យស្នើសុំ ដើម្បីកំណត់ថាតើតក្កកម្មត្រូវបានបង្ហាញក្នុងលក្ខណៈគ្រប់គ្រាន់ដែលអាចឱ្យបុគ្គលដែលមានជំនាញក្នុងវិស័យនេះអាចបង្កើត ឬប្រើប្រាស់តក្កកម្មនោះបាន ។ ដោយផ្តល់នូវការពិពណ៌នាជាលាយលក្ខណ៍អក្សរគ្រប់គ្រាន់ដើម្បីអាចឲ្យគេអនុវត្តតក្កកម្មបានជាទូទៅជាអ្វីដែលអ្នកស្នើសុំប្រកាសនីយប័ត្រតក្កកម្មត្រូវផ្តល់ឱ្យដើម្បីដោះដូរនឹងការទទួលបានអត្ថប្រយោជន៍ពីប្រកាសនីយប័ត្រតក្កកម្មនេះ ។

អនុសញ្ញាទីក្រុងប៉ារីសស្តីពី កិច្ចការពារកម្មសិទ្ធិឧស្សាហកម្មឆ្នាំ១៨៨៣ដែលជាអនុសញ្ញាចាស់បំផុតដែលគ្រប់គ្រងដោយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដែលពាក់ព័ន្ធនឹងកម្មសិទ្ធិឧស្សាហកម្មបានចែងអំពី '**សិទ្ធិជាអាទិភាព**' ។ ផ្អែកលើមូលដ្ឋាននៃពាក្យស្នើសុំដ៏ត្រឹមត្រូវលើកដំបូងដែលបានដាក់នៅក្នុង

ប្រទេសហត្ថលេខីណាមួយសិទ្ធិនេះមានន័យថា អ្នកស្នើសុំនោះអាចដាក់ពាក្យស្នើសុំការពារនៅក្នុងប្រទេសហត្ថលេខីណាមួយផ្សេងទៀតបាននៅក្នុងកំឡុងពេលដប់ពីរ(១២)ខែ ។ ពាក្យស្នើសុំបន្ទាប់នេះត្រូវចាត់ទុកថាបានដាក់នៅកាលបរិច្ឆេទដូចគ្នានឹងពាក្យស្នើសុំលើកដំបូងដែរ។ម្យ៉ាងទៀតពាក្យស្នើសុំបន្ទាប់នេះនឹងមានអាទិភាពលើសពីពាក្យស្នើសុំដែលបានដាក់ពាក្យក្នុងរយៈពេលដំណាលគ្នា ដោយបុគ្គលផ្សេងទៀតសម្រាប់តក្កកម្មដែលដូចគ្នា ។

អ្នកអាចត្រូវបានពីអត្ថប្រយោជន៍នៃប្រកាសនីយប័ត្រតក្កកម្ម ជាពិសេស ប្រសិនបើ តក្កកម្មត្រូវបានបញ្ចេញឲ្យគេដឹងឮ ។ ជាទូទៅចម្លើយគឺថាក្នុងរយៈពេលនៃកិច្ចការពារម្ចាស់ប្រកាសនីយប័ត្រតក្កកម្មអាចរារាំងបុគ្គលដទៃមិនឲ្យបង្កើត ប្រើប្រាស់ ដាក់លក់ លក់ និងនាំចូលតក្កកម្មដែលអះអាងឱ្យការពារ ។ ប៉ុន្តែ ម្ចាស់ប្រកាសនីយប័ត្រតក្កកម្មមានសិទ្ធិផ្ទេរ(លក់) ឬផ្តល់អាជ្ញាប័ណ្ណប្រកាសនីយប័ត្រតក្កកម្មនេះបាន ។ ម្យ៉ាងទៀត ម្ចាស់ប្រកាសនីយប័ត្រតក្កកម្មអាច ប្រសិនបើគាត់ចង់ ផ្ទេរសិទ្ធិផ្តាច់មុខទៅឱ្យបុគ្គលណាមួយផ្សេងទៀតតាមរយៈការចុះកិច្ចសន្យាអាជ្ញាប័ណ្ណ ។

ចូរអ្នកស្តាប់សម្លេងបន្ទាប់សម្រាប់សិក្សាបន្ថែមលើចំណុចនេះ ។

**ភាគនៃសម្លេងភាគទី៥ :តើអ្នកអាចសង្ខេបអំពីអត្ថប្រយោជន៍ស្តីពីការទទួលបានប្រកាសនីយប័ត្រតក្កកម្មនេះ បានដែរឬទេ ?**

អត្ថប្រយោជន៍ដែលទទួលបានពីប្រកាសនីយប័ត្រតក្កកម្មគឺថាម្ចាស់ប្រកាសនីយប័ត្រតក្កកម្មអាចរារាំងបុគ្គលដទៃនៅក្នុងទឹកដីដែលគ្របដណ្តប់ដោយប្រកាសនីយប័ត្រតក្កកម្ម មិនឱ្យបង្កើត ប្រើប្រាស់ លក់ស្តុកសម្រាប់លក់ ឬការនាំចូលតក្កកម្ម ។ នេះមិនចាំបាច់ផ្តល់ដល់តក្កករ ឬម្ចាស់ប្រកាសនីយប័ត្រតក្កកម្មនូវសិទ្ធិប្រើប្រាស់តក្កកម្មនោះឡើយ ប្រសិនបើ ជាឧទាហរណ៍ការប្រើប្រាស់នោះមិនស្របច្បាប់ដូចជាការប្រើប្រាស់ម៉ាស៊ីនលេងល្បែងស៊ីសង ប៉ុន្តែម្ចាស់ប្រកាសនីយប័ត្រតក្កកម្មអាចរារាំងបុគ្គលដទៃពីការធ្វើទីផ្សារ ឬទាញយកផលប្រយោជន៍ពីតក្កកម្មនោះនៅក្នុងរយៈពេលច្រើនឆ្នាំ ។

រយៈពេលកំណត់នៃប្រកាសនីយប័ត្រតក្កកម្មមួយ ជាទូទៅម្ភៃ(២០)ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ ហើយក្នុងរយៈពេលនេះបានផ្តល់ដល់អ្នកបង្កើតបច្ចេកវិទ្យានូវសិទ្ធិក្នុងរយៈពេលកំណត់មួយ ជាថ្នូរនឹងការបង្ហាញពីរបៀបប្រើប្រាស់តក្កកម្មជាសាធារណៈ។ ក្នុងករណីដែលសិទ្ធិនៃប្រកាសនីយប័ត្រតក្កកម្មផុតកំណត់ បច្ចេកវិទ្យានឹងក្លាយជាទ្រព្យសម្បត្តិសាធារណជន ហើយសាធារណជនអាចប្រើប្រាស់ប្រកាសនីយប័ត្រតក្កកម្មដោយសេរីសម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន ។

**អ្នកបានលើកឡើងថាម្ភៃ(២០)ឆ្នាំ ។ តើមានលក្ខណៈដូចគ្នាដែរឬទេ សម្រាប់ប្រទេសទាំងអស់នៅលើពិភពលោក ?**

បាទ/ចាស។ ឥឡូវនេះ បញ្ហានេះមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិថារយៈពេលយ៉ាងតិចម្ភៃ(២០)ឆ្នាំដោយគិតចាប់ពីកាលបរច្ឆេទនៃការដាក់ពាក្យស្នើសុំប្រកាសនីយប័ត្រតក្កកម្ម ។

មានសភាពការណ៍មួយចំនួនដែលសិទ្ធិផ្តាច់មុខរបស់ម្ចាស់ប្រកាសនីយប័ត្រតក្កកម្ម អាចត្រូវបានប្រើប្រាស់ដោយគ្មានការអនុញ្ញាតពីគាត់ ។

តាមការពិត ក្នុងករណីមួយចំនួនការប្រើប្រាស់តក្កកម្មដែលទទួលបានប្រកាសនីយប័ត្រតក្កកម្មអាចអនុញ្ញាតឲ្យភាគីទី៣ដោយបតុលាការមានសមត្ថកិច្ចឬការិយាល័យប្រកាសនីយប័ត្រតក្កកម្ម ( ដោយផ្អែកតាមច្បាប់របស់ប្រទេសនោះ ) តាមរយៈអាជ្ញាប័ណ្ណបញ្ជា ។ ដូចមានចែងនៅក្នុងអនុសញ្ញាទីក្រុងប៉ារីស និងកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា របបអាជ្ញាប័ណ្ណបញ្ជារទប់ស្កាត់ការរំលោភបំពាន ដែលអាចបណ្តាលមកពីសិទ្ធិផ្តាច់មុខដែលទទួលបានប្រកាសនីយប័ត្រតក្កកម្ម ។ របបនេះអាចត្រូវបានអនុវត្តផងដែរនៅក្នុងករណីដែលមិនបានប្រើប្រាស់តក្កកម្មដែលទទួលបានប្រកាសនីយប័ត្រតក្កកម្មនោះនៅក្នុងរយៈពេលមួយដែលបានបញ្ញត្តិ(ជាទូទៅបួន(៤)ឆ្នាំដោយគិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំប្រកាសនីយប័ត្រតក្កកម្ម ) ឬបី(៣)ឆ្នាំដោយគិតចាប់ពីចេញប្រកាសនីយប័ត្រតក្កកម្ម ។

ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងស្តីពី ទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា ( មាត្រា៣១ ) លក្ខខ័ណ្ឌនិងកាលៈទេសៈមួយចំនួនត្រូវបានគោរពមុនពេលផ្តល់អាជ្ញាប័ណ្ណបញ្ជារទៅឲ្យភាគីទី៣នោះ

## សំណួរវាយតម្លៃខ្លួនឯង

**SAQ ៤: តើអ្នកណាខ្លះត្រូវបានអនុញ្ញាតមិនឲ្យអ្នកដ៏ទៃមានសិទ្ធិបង្កើត ប្រើប្រាស់ លក់ តាំងលក់ ឬនាំចូលតក្កកម្ម ?**

ចូរអ្នកសរសេរចម្លើយរបស់អ្នក នៅត្រង់នេះ:

| |
|---|
| |

ចូរអ្នកចុចត្រង់នេះ ដើម្បីមើលចម្លើយ

**SAQ ៩ចម្លើយ:**

ម្ចាស់ប្រកាសនីយប័ត្រតក្កកម្មអាចរាំងបុគ្គលដ៏ទៃមិនឲ្យបង្កើត ប្រើប្រាស់ លក់ ដាក់លក់ឬនាំចូលតក្កកម្មដែលទទួលបានប្រកាសនីយប័ត្រតក្កកម្មរួចហើយ និងអាចធ្វើការបដិសេធការធ្វើការពាណិជ្ជកម្មផងដែរ ។ ការបដិសេធនេះអាចអនុវត្តបានតែនៅក្នុងប្រទេសដែលតក្កកម្មត្រូវបានការពារដោយប្រកាសនីយប័ត្រតក្កកម្មប៉ុណ្ណោះ។

នៅក្នុងន័យមួយទៀត ប្រកាសនីយប័ត្រតក្កកម្មគឺជាទំនាក់ទំនងរវាងសាធារណៈជន និងអ្នកកាន់កាប់ប្រកាសនីយប័ត្រតក្កកម្ម ។ ជាមួយនឹងការផ្តល់ប្រកាសនីយប័ត្រតក្កកម្មដែលបានបំពេញរាល់លក្ខខ័ណ្ឌទាំងអស់សម្រាប់ការទទួលបានប្រកាសនីយប័ត្រតក្កកម្ម ដូចដែលបានពិភាក្សាខាងលើ ម្ចាស់ប្រកាសនីយប័ត្រតក្កកម្មទទួលបានសិទ្ធិ ដើម្បីរាំងបុគ្គលដទៃមិនឲ្យអនុវត្តតក្កកម្មដែលបានអះអាងនៅក្នុងប្រកាសនីយប័ត្រតក្កកម្មនោះ ។ ដោយការទាមទារឱ្យបំពេញលក្ខខណ្ឌដើម្បីទទួលបានប្រកាសនីយបត្រតក្កកម្មជាថ្នូររដ្ឋាភិបាលត្រូវធានាថា ព័ត៌មានស្តីពីតក្កកម្មត្រូវបានបញ្ចេញឲ្យសាធារណៈជនដឹង ហើយតក្កកម្មអាចប្រើប្រាស់បានដោយបុគ្គលណាមួយបន្ទាប់ពីផុតកំណត់រយៈពេលការពារដោយប្រកាសនីយប័ត្រតក្កកម្ម ។ ជាទូទៅមានរយៈពេលម្ភៃ(២០)ឆ្នាំគិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំប្រកាសនីយប័ត្រតក្កកម្ម ។

នៅគ្រប់ប្រទេសដែលអ្នកកាន់កាប់ប្រកាសនីយប័ត្រតក្កកម្មសម្រេចជ្រើសរើសយកកិច្ចការពារតក្កកម្មដោយប្រកាសនីយប័ត្រតក្កកម្មបញ្ហា នៃការអនុវត្តសិទ្ធិអាចជារឿងមួយដ៏សំខាន់បន្ទាប់បានផ្តល់កិច្ចការពារ។ ការអនុវត្តប្រកាសនីយប័ត្រតក្កកម្មជាកម្មវត្ថុដ៏ទូលាយដែលក្នុងការសិក្សានេះលើកឡើងតែពីគោលការណ៍ណែនាំដែលពាក់ព័ន្ធប៉ុណ្ណោះ។

មានតែអ្នកកាន់កាប់ប្រកាសនីយប័ត្រតក្កកម្មប៉ុណ្ណោះ ដែលផ្តួចផ្តើមគំនិតមុនគេពាក់ព័ន្ធនឹងការរំលោភដែលមានសក្តានុពល។ ការរកឃើញការរំលោភដែលមានសក្តានុពល ឬពិតប្រាកដ និងចាត់វិធានការចំពោះជនល្មើជាសិទ្ធិផ្តាច់របស់ម្ចាស់ប្រកាសនីយប័ត្រតក្កកម្ម ។

ករណីភាគច្រើនគឺការផ្ញើលិខិតគួរសមជូនដំណឹងជាមុនពីអត្ថិភាពនៃប្រកាសនីយប័ត្រតក្កកម្ម ។ បន្ទាប់មកអាចមានបណ្តឹង លិខិតបែបនេះជាទូទៅបានបង្ហាញពីការទទួលបានជោគជ័យដែលឈានទៅដល់ការបង្ក្រាបលើការរំលោភឬការចុះកិច្ចសន្យាអាជ្ញាប័ណ្ណប្រកបដោយជោគជ័យ ។

យ៉ាងណាក៏ដោយក៏មានករណីដែលមិនអាចឈានដល់ដំណោះស្រាយដែលមានប្រយោជន៍សងខាងតាមរយៈការចរចាសូម្បីតែមានការព្យាយាមអស់រយៈពេលដ៏យូរក៏ដោយ ។ នៅក្នុងចន្លោះនៃបណ្តឹងពីការរំលោភបំពានក្នុងដំណាក់កាលមុនជំនុំជំរះនៅតែមានការចរចានៅតែតាមរយៈការប្រើប្រាស់អ្នកសម្របសម្រួល ឬមជ្ឍត្តករ ។ គួរឲ្យចាប់អារម្មណ៍ ដំណោះស្រាយតែងតែរួមមានការផ្តល់អាជ្ញាប័ណ្ណដែលបានលើកឡើងខាងលើ ។

ដូចបានលើកឡើងខាងដើម បញ្ហានៃការអនុវត្តសិទ្ធិមានលក្ខណៈស៊ីជម្រៅនិងស្មុគ្រស្មាញ ។ អ្នកអាចបន្តស្វែងយល់ពីកម្មវត្ថុនេះបន្ថែមនៅក្នុងបរិបទនៃច្បាប់ជាតិដែលអ្នករស់នៅ ។
ដើម្បីទទួលបានកិច្ចការពារនៅក្នុងប្រទេសផ្សេងៗតម្រូវឲ្យមានប្រកាសនីយប័ត្រតក្កកម្មនៅក្នុងប្រទេសនីមួយៗ ។ ដូច្នេះអ្នកអាចឆ្ងល់ថាអាចទៅរួចឬទេ ដើម្បីទទួលបានបានប្រកាសនីយប័ត្រតក្កកម្មទូទាំងពិភពលោល ។ ចូរអ្នកស្តាប់សម្លេងដើម្បីស្វែងរកចម្លើយ ។

## ភាគនៃសម្លេងភាគទី៦ : តើអាចទៅរួចដែរ ឬទេ ដើម្បីទទួលបានប្រកាសនីយប័ត្រតក្កកម្មទូទាំងពិភពលោក ?

គ្មានទេក្នុងប្រព័ន្ធប្រកាសនីយប័ត្រតក្កកម្មអន្តរជាតិបច្ចុប្បន្ន ។ គ្មានប្រកាសនីយប័ត្រតក្កកម្មណាមួយអាចគ្របដណ្តប់ទូទាំងពិភពលោកបានទេ ឬសូម្បីតែប្រទេសភាគច្រើននៅលើពិភពលោកនោះ ។ ប្រព័ន្ធប្រកាសនីយប័ត្រតក្កកម្មនៅតែជាប្រព័ន្ធដែនដីនៅឡើយ ។ ដើម្បីការពារឲ្យបាននៅក្នុងប្រទេសណាមួយ អ្នកត្រូវតែបានផ្តល់ប្រកាសនីយប័ត្រតក្កកម្មនៅប្រទេសនោះ ។ ឥឡូវនេះ ជាមួយនឹងសកលភាវូនីយកម្មសេដ្ឋកិច្ចពិភពលោក មានការឈានរកប្រព័ន្ធអន្តរជាតិ យើងមានសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្ម(PCT)ដែលមានចែងពីការដាក់ពាក្យសំណុំលិខិតស្នើសុំអន្តរជាតិតែមួយដែលអាចក្លាយជាសំណុំលិខិតស្នើសុំថ្នាក់ជាតិជាច្រើនមិនមែនជាប្រកាសនីយប័ត្រតក្កកម្មនោះទេគឺគ្រាន់តែជាពាក្យស្នើសុំប៉ុណ្ណោះ ហើយបន្ទាប់មកសំណុំលិខិតស្នើសុំទាំងនោះនឹងត្រូវបានត្រួតពិនិត្យក្នុងប្រទេសនីមួយៗដែលបានកំណត់ ។

មានប្រព័ន្ធថ្នាក់តំបន់មួយចំនួនដូចជា អង្គភាពប្រកាសនីយប័ត្រតក្កកម្មអឺរ៉ុបក្រោមការត្រួតពិនិត្យតែមួយ ប្រសិនបើជោគជ័យអាចទទួលបានប្រកាសនីយបត្រតក្កកម្មក្នុងក្រុមប្រទេសទាំងនោះ។ មានកិច្ចពិភាក្សាមួយចំនួននៅអឺរ៉ុប ស្តីពី ការទទួលបានប្រកាសនីយប័ត្រតក្កកម្មនៅសហគមអឺរ៉ុបប្រកាសនីយប័ត្រតក្កកម្មមួយដែលគ្របដណ្តប់ប្រទេសទាំងឡាយនៃសហភាពអឺរ៉ុប ទោះបីជាមានការលំបាកខ្លាំងក៏ដោយដែលអ្នកអាចស្រមៃឃើញ ។ នៅតែពុំមានរឿងបែបនេះថាមានប្រកាសនីយប័ត្រតក្កកម្មលក្ខណ:ពិភពលោក ឬពុំមានផែនការណាសម្រាប់ប្រកាសនីយប័ត្រតក្កកម្មបែបនេះឡើយពីព្រោះមានការលំបាកយ៉ាងខ្លាំង ក៏ប៉ុន្តែកិច្ចពិភាក្សានៅតែបន្តដើម្បីរិះរកវិធីកាត់បន្ថយការចំណាយក្នុងការទទួលបាននូវកិច្ចការពារប្រកាសនីយប័ត្រតក្កកម្មទូទាំងពិភពលោក ។

ក្នុងចំណោមចំណាយផ្សេងៗ មានការចំណាយលើរាល់ការត្រួតពិនិត្យតក្កកម្មតែមួយនៅក្នុងប្រទេសផ្សេងៗ ការចំណាយលើការបកប្រែ និងចំណាយលើការរក្សាប្រកាសនីយប័ត្រតក្កកម្មដើម្បីរក្សាប្រកាសនីយប័ត្រតក្កកម្មឱ្យមានសុពលភាព ដែលជាទូទៅត្រូវបង់ជាប្រចាំឆ្នាំដែលអាចមានសារ:សំខាន់ណាស់ ។

**ហើយតើអ្នកត្រូវបង់កម្រៃប្រចាំឆ្នាំនៅគ្រប់ប្រទេសដែលអ្នកចង់បានប្រកាសនីយប័ត្រតក្កកម្មនោះឬ ?**

ត្រឹមត្រូវហើយ ។ ប្រសិនបើអ្នកទទួលបានប្រកាសនីយប័ត្រតក្កកម្មនៅក្នុងដប់ប្រទេស អ្នកត្រូវបង់កម្រៃរក្សានៅក្នុងប្រទេសនីមួយៗក្នុងចំណោមប្រទេសទាំងដប់នោះ ពីព្រោះប្រសិនអ្នកខកខានបង់នៅក្នុងប្រទេសណាមួយ ប្រកាសនីយប័ត្រតក្កកម្មរបស់អ្នកនោះក្នុងប្រទេសនោះ អាចអស់សុពលភាព ហើយអ្នកត្រូវបាត់បង់កិច្ចការពារប្រកាសនីយប័ត្រតក្កកម្មរបស់អ្នក ។

**នៅក្នុងប្រទេសនោះឬ ?**

ត្រឹមត្រូវហើយ ។

ហេតុដូច្នេះ ចម្លើយយ៉ាងខ្លីគឺ " ទេ " ។ ទោះបីយ៉ាងណាក៏មានកិច្ចព្រមព្រៀងអន្តរជាតិមួយដែលគ្រប់គ្រងដោយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ហៅថាសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្ម ( PCT )សម្រាប់ការដាក់ពាក្យ ការស្រាវជ្រាវ ការបោះពុម្ព និងការត្រួតពិនិត្យពាក្យស្នើសុំអន្តរជាតិ ។ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មធ្វើឲ្យមានភាពងាយស្រួលដល់ការទទួលបានប្រកាសនីយប័ត្រតក្កកម្មនៅក្នុងប្រទេសហត្ថលេខី តាមរយ:ការការដាក់ពាក្យស្នើសុំអន្តរជាតិតែមួយដែលអាចត្រូវបានត្រួតពិនិត្យនៅបការិយាល័យ នៃប្រទេស ឬតំបន់ដែលជាភាគីហត្ថលេខីនៃសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្ម ។ ( ម៉ូឌុលបន្ទាប់ស្តីពីប្រព័ន្ធចុះបញ្ជីអន្តរជាតិនៃ

អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដែលគ្រប់ដណ្តប់លើសន្ធិសញ្ញានៃសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្ម និងកិច្ចព្រមព្រៀងអន្តរជាតិចំនួនពីរផ្សេងៗទៀតលក្ខណៈស៊ីជម្រៅ )។ ទោះបីយ៉ាងណាសូម្បីតែនៅក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្ម ការផ្តល់ប្រកាសនីយប័ត្រតក្កកម្មត្រូវបានទុកឲ្យការិយាល័យដែលបានកំណត់នោះ ។

អ្នកនឹងសិក្សាបន្ថែមពីសន្ធិសញ្ញាទាំងនេះនៅក្នុងម៉ូឌុលស្តីពី សន្ធិសញ្ញានៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោកនៅវគ្គនេះ ។

ជាទីបញ្ចប់ គួរចងចាំថាកិច្ចការពារប្រកាសនីយប័ត្រតក្កកម្មគឺជាវិធីមួយគត់សម្រាប់ការពារតក្កកម្ម ។ ចូរអ្នកស្តាប់សម្លេងដើម្បីរិះរកវិធីការពារផ្សេងទៀត ។

## ភាគនៃសម្លេងភាគទី៧: តើមានវិធីការពារតក្កកម្មផ្សេងទៀតដែរឬទេ ក្នុងករណីដែលអ្នកមិនចង់ការពារដោយប្រកាសនីយប័ត្រតក្កកម្មដោយហេតុផលអ្វីក៏ដោយ ?

ប្រកាសនីយប័ត្រតក្កកម្មជាវិធីការពារតក្កកម្មដ៏មានប្រសិទ្ធភាពបំផុត ប៉ុន្តែដូចដែលបានលើកឡើងពីខាងដើម សិទ្ធិប្រកាសនីយប័ត្រតក្កកម្មត្រូវបានផ្តល់ឱ្យជាថ្នូនឹងការបង្ហាញតក្កកម្មពេញលេញដោយតក្ករជាសាធារណៈ។ វិធីដែលមានប្រសិទ្ធិភាពមួយផ្សេងទៀតក្នុងការទទួលបាននូវកិច្ចការពារគឺត្រូវរក្សាជាសម្ងាត់នៃបច្ចេកវិទ្យាដែលហៅថាការសម្ងាត់ពាណិជ្ជកម្ម ដើម្បីរក្សាព័ត៌មានស្តីពីតក្កកម្មជាសម្ងាត់ ។ ផលវិបាកនៃវិធីសាស្រ្តនោះគឺថានៅពេលដែលផលិតផលត្រូវបានដាក់លក់នៅលើទីផ្សារនិងអាចត្រូវបានគេរុះរើ ការសម្ងាត់អាចត្រូវបានគេស្វែងយល់ដោយគ្រាន់តែមើលលើផលិតផលនោះហើយកិច្ចការពារការសម្ងាត់ពាណិជ្ជកម្មត្រូវបានបាត់បង់ ។ ជាមួយនឹងប្រកាសនីយប័ត្រតក្កកម្មពុំមានបញ្ហាអ្វីទេទោះជាអ្នកដ៏ទៃដឹងពីវិធីបង្កើតផលិតផលរបស់អ្នក ពិតណាស់ពួកគេនឹងដឹងជាទូទៅតាមរយៈការអានសំណុំលិខិតស្នើសុំរបស់អ្នក ។ ដូច្នេះគ្មានបញ្ហាទេទោះជាព័ត៌មានត្រូវបានផ្សព្វផ្សាយជាសាធារណៈជនក៏ដោយករណីដែលអ្នកទទួលបានប្រកាសនីយប័ត្រតក្កកម្ម អ្នកនឹងនៅតែទទួលបានកិច្ចការពារ ។ ទោះបីយ៉ាងណាកិច្ចការពារការសម្ងាត់ពាណិជ្ជកម្មនៅតែមាននិងសក្តសមបំផុតក្នុងករណីមួយចំនួន សម្រាប់ចំណេះធ្វើដូចជាជំនាញបច្ចេកទេសដែលទាមទារប្រើប្រាស់បច្ចេកវិទ្យាណាមួយក្នុងវិធីដែលមានប្រសិទ្ធិភាពបំផុត ។ ហើយជាញឹកញាប់ បច្ចេកវិទ្យាផ្ទាល់នឹងមិនត្រូវបានការពារដោយប្រកាសនីយប័ត្រតក្កកម្មឡើយពីព្រោះវាជាផ្នែកនៃជំនាញរបស់មនុស្សដែលមានជំនាញក្នុងស្នាដៃនិងរក្សាជាចំណេះធ្វើជាការសម្ងាត់ពាណិជ្ជកម្មជាវិធីការពារបច្ចេកវិទ្យារបស់ខ្លួន ។

## សំណួរវាយតម្លៃខ្លួនឯង

**SAQ ភាគទី៥: ចូរអ្នកលើកជាឧទាហរណ៍មួយស្តីពី " កិច្ចការពារការសម្ងាត់ពាណិជ្ជកម្ម " នឹងត្រូវការពារយ៉ាងដូចម្តេចខ្លះ?**

ចូរអ្នកសរសេរចម្លើយរបស់អ្នកនៅទីនេះ:

ចូរអ្នកចុចត្រង់នេះដើម្បីមើលចម្លើយ

**ចម្លើយSAQ ៥**

អ្នកឧទ្ទេសនាមបានពិភាក្សាអំពីវិធីរក្សាការសម្ងាត់ពាណិជ្ជកម្ម ។ ជាឧទាហរណ៍Coca-Colaបានធ្វើរបៀបនេះជាង១០០ឆ្នាំមកហើយនិងនៅតែបន្តរក្សាបានជោគជ័យការសម្ងាត់រូបមន្តរបស់ខ្លួនដែលកិច្ចការពារកម្មសិទ្ធិបញ្ញានឹងនៅឋិតថេរយូរអង្វែងជាងប្រកាសនីយប័ត្រតក្កកម្ម។ ជាឧទាហរណ៍ការសម្ងាត់ពាណិជ្ជកម្មការពារចំណេះធ្វើ និងជំនាញបច្ចេកទេសដើម្បីប្រើប្រាស់ព័ត៌មានជាក់លាក់តាមវិធីដ៏មានប្រយោជន៍បំផុត ។

**សេចក្តីសង្ខេប**

ម៉ូឌីលនេះណែនាំអំពីវិស័យកម្មសិទ្ធិបញ្ញាខាងផ្នែកប្រកាសនីយប័ត្រតក្កកម្ម ។ ប្រកាសនីយប័ត្រតក្កកម្មជាទម្រង់ចាស់មួយស្តីពីកិច្ចការពារកម្មសិទ្ធិបញ្ញា ហើយដូចទម្រង់ទាំងអស់នៃការពារកម្មសិទ្ធិបញ្ញាដែរ គោលបំណងនៃប្រព័ន្ធប្រកាសនីយប័ត្រតក្កកម្មគឺលើកទឹកចិត្តដល់ការអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈការផ្តល់ជារង្វាន់ដល់ការច្នៃប្រឌិតខាងផ្នែកបញ្ញា។ម៉ូឌុលនេះបានពន្យល់ថាគោលបំណងនៃប្រព័ន្ធប្រកាសនីយប័ត្រតក្កកម្មនេះគឺលើកទឹកចិត្តដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងបច្ចេកវិទ្យាតាមរយៈការផ្តល់ជារង្វាន់ដល់ការច្នៃប្រឌិតខាងបញ្ញា ។

ក្រោមកិច្ចការពារប្រកាសនីយប័ត្រតក្កកម្មទាំងការបង្កើតថ្មីនិងការអភិវឌ្ឍបន្ថែមតក្កកម្មដែលមានស្រាប់ត្រូវបានការពារ ។ ការរកឃើញនូវអ្វីមួយដ៏សំខាន់នៅក្នុងវិទ្យាសាស្រ្តដូចជាតក្កកម្មនៃប៉េនីស៊ីលិនគឺមានសារៈសំខាន់និងត្រូវបានការពារដូចគ្នានឹងការបង្កើតម៉ាស៊ីនដែលមានដំណើរការលឿន ។ ប្រកាសនីយប័ត្រតក្កកម្មការពារតក្កកម្ម និងជាទូទៅតក្កកម្មត្រូវបានកំណត់ថាជាដំណោះស្រាយថ្មីអំពីបញ្ហា

បច្ចេកទេស ។ ដំណោះស្រាយគឺជា"គំនិត"ហើយកិច្ចការពារក្រោមច្បាប់ប្រកាសនីយប័ត្រតក្កកម្មមិនតម្រូវឲ្យតក្កកម្មមានតំណាងដោយវត្ថុនោះឡើយ ។ ទោះបីយ៉ាងណាក៏មានទំនិញមួយចំនួនដែលមិនអាចទទួលបាននូវប្រកាសនីយប័ត្រតក្កកម្មផងដែរ ។ កម្មវត្ថុទាំងនេះរួមមានវត្ថុដែលរកឃើញនៅក្នុងធម្មជាតិ និងម៉ាស៊ីនដែលផ្ទុយនឹងច្បាប់ធម្មជាតិដូចជាម៉ាស៊ីនធ្វើចលនាឥតឈប់ ។ ការលើកលែងផ្សេងៗទៀតដែលមានចែងនៅក្នុងច្បាប់រួមមានទ្រឹស្តីវិទ្យាសាស្ត្រ និងវិធីគណិតសាស្ត្រ ផែនការវិធាន និងវិធីធ្វើជំនួញ និងវិធីព្យាបាលមនុស្ស ឬសត្វ ឬវិធីនៃរោគវិនិច្ឆ័យ ។

នៅពេលដែលពាក្យស្នើសុំប្រកាសនីយប័ត្រតក្កកម្មត្រូវបានដាក់ពាក្យមានវិធីទូទៅពីរយ៉ាង ៖ នៅក្នុងប្រទេសខ្លះ ពាក្យស្នើសុំនេះត្រូវបានពិនិត្យឡើងវិញត្រឹមតែបែបបទប៉ុណ្ណោះ រីឯយុត្តាធិការផ្សេងទៀតពិនិត្យខ្លឹមសារនៃពាក្យស្នើសុំផងដែរដោយអ្នកជំនាញបច្ចេកទេស ដើម្បីធានាថាបានបំពេញល័ក្ខខ័ណ្ឌត្រឹមត្រូវនៃភាពដែលអាចទទួលបានប្រកាសនីយប័ត្រតក្កកម្ម ។ លក្ខណៈដែលតក្កកម្មត្រូវមានគឺ ៖

- តក្កកម្មត្រូវតែថ្មី
- តក្កកម្មត្រូវតែមានជំហានរកឃើញថ្មី
- តក្កកម្មត្រូវតែអាចយកទៅអនុវត្តបាននៅក្នុងវិស័យឧស្សាហកម្ម។

ជារួមប្រកាសនីយប័ត្រតក្កកម្មពាក់ព័ន្ធរវាងសាធារណជននិងតក្កករ។ កិច្ចការពារសម្រាប់ពេលវេលាមួយដែលមានកំណត់ធានាថាតក្កករត្រូវបានទទួលរង្វាន់ ។ បន្ទាប់ពីផុតកំណត់រយៈពេលការពារជាទូទៅមានរយៈពេលម្ភៃ(២០)ឆ្នាំបន្ទាប់ពីកាលបរិច្ឆេទ នៃការដាក់ពាក្យស្នើសុំប្រកាសនីយប័ត្រតក្កកម្មតក្កកម្មនោះនឹងក្លាយជាទ្រព្យសម្បត្តិរបស់មហាជន។ ។ ការអនុវត្តប្រកាសនីយប័ត្រតក្កកម្មរបស់នរណាម្នាក់គឺជាកម្មវត្ថុមួយដ៏ទូលំទូលាយ ហើយគឺម្ចាស់ប្រកាសនីយប័ត្រតក្កកម្មដែលត្រូវធ្វើការចរចាឬប្តឹងអំពីការរំលោភនូវសិទ្ធិរបស់ខ្លួន។ដោយសារគ្មានកិច្ចការពារជាលក្ខណៈសាកលតក្កករត្រូវបង់ថ្លៃសេវានៃការដាក់ពាក្យស្នើសុំ និងកម្រៃរក្សាសិទ្ធិសេវាក្នុងប្រទេសនីមួយៗដែលគេមានបំណងចង់បានការពារនោះ។

**អត្ថបទច្បាប់:**

_អនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ។
_ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្ម (PCT) ។
_កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS- Agreement) ។

**អង្គការកម្មសិទ្ធិបញ្ញាពិភពលោក(WIPO/OMPI)**